ស្បៃខ្មែរ

នៅក្នុងវចនានុក្រមខ្មែរ ពាក្យថា "**ស្បៃ**" សំដៅលើសំពត់សាច់ស្តើងបើងរ៉ើង។ យោងតាមឯកសាររបស់អគ្គនាយកដ្ឋានបេតិកភណ្ឌវប្បធម៌អូរបី និងឧស្សាហកម្មវប្បធម៌ថ្មៃប្រតិដ្ឋ បានស្នើថា ស្ត្រីខ្មែរពីបុរាណប្រើប្រាស់ស្បៃក្នុងគោលបំណងចម្បងពីរ។ ទី១ ប្រើប្រាស់ក្នុងសកម្មភាពប្រចាំថ្ងៃ សម្រាប់គ្របដណ្តប់កាយ ឬបំបាត់រដា និងទី២ គេប្រើប្រាស់ដើម្បីសោភ័ណភាពក្នុងឈុតសម្លៀកបំពាក់ប្រពៃណីពេលចេញក្រៅផ្ទះ ឬចូលរួមពិធីបុណ្យទាននិងកម្មវិធីវប្បធម៌ផ្សេងៗ។ ម្ល៉ោះហើយ ស្បៃមិនត្រឹមតែជាគ្រឿងសម្លៀកបំពាក់នោះទេ ប៉ុន្តែវាជានិមិត្តរូបតំណាងឱ្យភាពថ្លៃថ្នូរ សុភាពរាបសារ និងលក្ខណៈដ៏ឧត្តុង្គឧត្តមរបស់ស្ត្រីខ្មែរ។

ការប្រើប្រាស់ស្បៃសម្រាប់គ្របដណ្តប់កាយរបស់ស្ត្រីខ្មែរ មិនមែនទើបតែមាននាពេលថ្មីៗនេះទេ ពោល គឺមានប្រវត្តិប្រើប្រាស់ជាយូរលង់ណាស់មកហើយ។ យ៉ាងហោចណាស់ ក៏យើងអាចដឹងថា ការប្រើប្រាស់ស្បៃមានតាំងពីស.វ.ទី៧ មកម៉្លេះ ដោយយោងទៅលើកស្តូតាងសិលាចារឹកជាតឹកតាង។ ក្នុងនោះ សិលាចារឹកវត្តគំនូរ ឬគេស្គាល់ថាសិលាចារឹកអង្គរបុរី ខេត្តតាកែវ ចុះលេខបញ្ជី K.600 ចារឹកជាភាសាខ្មែរនៅឆ្នាំ៦១១នៃគ្រិស្តសករាជ បានបញ្ជាក់ឱ្យដឹងថា៖ *ម្រតាញ អន្តារ បានថ្វាយអ្នកចម្រៀងចំនួន១១នាក់ ថ្វាយជូនដល់ព្រះកម្រតាងអញ.....ស្ងរ និងកម្រតាងអញតេំក្រាំ(ដើមក្រោម)* ដែលអ្នកចម្រៀងទាំងនោះមានឈ្មោះនិងលក្ខណៈសម្គាល់ប្លែកៗពីគ្នា។ ក្នុងចំណោមអ្នកចម្រៀងទាំងនោះមានឈ្មោះដូចជា **តន្ទង្គី** (នារីដែលមានពងស្តើងស្អាត), **គុណធារី** (នារីដែលមានគុណធម៌), **បយោធារី** (នារីដែលមានដើមទ្រូងស្អាត) ។ល។ ប៉ុន្តែ អ្វីដែលយើងគួរកត់សម្គាល់ជាងគេនោះគឺ នារីដែលមានឈ្មោះថា "**សុនោត្តរី**" ដែលឈ្មោះនេះមានប្រភពពីភាសាសំស្ក្រឹត ដោយមានពាក្យពីរបូកបញ្ចូលគ្នា គឺ "**សុន**" ប្រែថា សុដន់ ឬដើមទ្រូង និងពាក្យថា "**ឧត្តរី**" ប្រែថា ក្រណាត់លើ, ស្បៃគ្របស្មា។ ហេតុដូច្នេះ ពាក្យថា "**សុនោត្តរី**" មានន័យថា "ស្បៃបាំងសុដន់" ឬ "ក្រណាត់សម្រាប់គ្របដើមទ្រូង" ពោល គឺចង់សំដៅទៅលើនារីជាអ្នកចម្រៀងម្នាក់ដែលមានស្បៃបាំងសុដន់ ឬក្រណាត់បាំងដើមទ្រូង ដែលទំនងត្រូវនឹង "ស្បៃ" ដែលយើងហៅសព្វថ្ងៃនេះឯង។

កស្តូតាងដ៏សំខាន់មួយទៀត ត្រូវបានគេប្រទះឃើញនៅក្នុងសិលាចារឹកប្រាសាទព្រះគោ ខេត្តសៀមរាប ចុះបញ្ជីលេខ K.713 ចារឹកនៅឆ្នាំ៨៩៣នៃគ្រិស្តសករាជ (ស.វ.ទី៩) ក្នុងរជ្ជកាល

ព្រះបាទស្រីយសោវរ្ម័នទី១ (គ.ស.៨៨៩ - ៩១០)។ សិលាចារឹកព្រះគោនេះបានរៀបរាប់ថា "នៅមហាសកពជឆ្នាំ៨១៥ ថ្ងៃទី៣កើត ខែវិសាខ ព្រះពជបញ្ជារបស់ព្រះករុណាព្រះកម្រតេង៑អញ្ជ្រើយសោវម្ម៌ទេវ បានថ្វាយតង្វាយជាមាស ប្រាក់ និង៑អ្នកបម្រើ ថ្វាយដល់ព្រះកម្រតេង៑អញ្ជតព្រះបរមេស្វរ។ នៅក្នុង៑ចំណោមទាំង៑នោះ មានតង្វាយដ៏គួរឱ្យចាប់អារម្មណ៍មួយដែលគេសរសេរថា៖ **"ព្រះស្បៃឫរអង្រ្គៅមមាសដើជមាស១"** ដែលនៅត្រង់ឃ្លានេះត្រូវបានលោក George Coedès សន្និដ្ឋានថា **"ស្បៃមួយបែបដែលមានរង៑ជើង៑ធ្វើពីសរសៃសូត្រមាស"**។

ដោយឡែក កស្តុតាង៑ចម្លាក់នៅតាមប្រាសាទបុរាណ ក៏កាន់តែបញ្ជាក់ឱ្យកាន់តែច្បាស់អំពីការប្រើប្រាស់ស្បៃរបស់ស្ត្រីខ្មែរ។ ឧទាហរណ៍ ចម្លាក់អប្សរពាសស្បៃធ្លាក់នៅជញ្ជាំង៑ប្រាសាទអង្គរវត្ត (ស.វ.ទី១២) និង៑ចម្លាក់ស្ត្រីពាសស្បៃ ធ្លាក់នៅជញ្ជាំង៑ថែវខាង៑ជើង៑ ស្ថាបខាង៑កើតនៃប្រាសាទអង្គរវត្ត (ស.វ.ទី១៦)។ ក្រៅអំពីនេះ ការបង្ហាញតាមរយៈគំនូរបុរាណនៅតាមវត្តអារាម ក៏បានបង្ហាញអំពីរូបភាពស្ត្រីខ្មែរពាសស្បៃដូចគ្នា ដែលរូបភាពទាំង៑នោះច្រើនបង្ហាញនៅក្នុង៑គំនូររឿងរាមកេរ្តិ៍ រឿងជាតក និង៑ពុទ្ធប្រវត្តិ ឧទាហរណ៍ គំនូរនៅជញ្ជាំង៑ព្រះវិហារវត្តក្តីដើម ខេត្តកំពង់ធំ គូរនៅទសវត្សរ៍១៩៣០ជាដើម។ ក្រៅអំពីនេះទៅទៀត តាមរឿងព្រេង **"ព្រះថោង៑នាង៑នាគ"** បានបង្ហាញឱ្យឃើញនូវប្បធម៌នៃការប្រើប្រាស់ស្បៃកាន់តែច្បាស់ និង៑បន្តមកទល់សព្វថ្ងៃ ពោល គឺជាប់ទាក់ទង៑នឹង៑ពិធីមង្គលការដែលកូនកំលោះត្រូវដើរពីក្រោយនិង៑តោង៑ស្បៃកូនក្រមុំ ដើម្បីត្រាប់តាមបុព្វការីជន។

យោង៑ទៅតាមការសិក្សារបស់អគ្គនាយកដ្ឋានបេតិកភណ្ឌវប្បធម៌អរូបី និង៑ឧស្សាហកម្មវប្បធម៌ច្នៃប្រតិដ្ឋ នៃក្រសួង៑វប្បធម៌ និង៑វិចិត្រសិល្បៈ បានបង្ហាញថា ស្បៃមានច្រើនប្រភេទខុសៗគ្នា អាស្រ័យលើប្រភេទសាច់កំណាត់ រូបរាង៑ និង៑របៀបត្រង៑។ ក្នុង៑នោះ ស្បៃសំខាន់ៗមានចំនួន ៧ ប្រភេទ ដូចខាង៑ក្រោម៖

- (១). **ស្បៃខ្សៀល ឬស្បៃវៀល** ជាស្បៃមួយប្រភេទមានរូបរាង៑ខ្សៀលបញ្ចិតពីឆ្វេង៑ទៅស្តាំ មានប្រវែង៑ជាមធ្យមគ្របជិតត្រគាកចន្លោះពី១,៦០ម៉ែត្រ ដល់២,៥ម៉ែត្រ និង៑ទទឹង៑ចាប់ពី០,៦ម៉ែត្រឡើង៑ទៅ ហើយគេនិយមប្រើក្នុង៑របាំបុរាណ (របាំព្រះពជទ្រព្យ ទេពមនោរម្យ មុនីមេខលា) ល្ខោនខោល និង៑ពិធីមង្គលការ។
- (២). **ស្បៃធ្យៀង** ជាស្បៃមានរូបរាង៑ស្ទើរតែដូចស្បៃខ្សៀលដែរ តែមានប្រវែង៑ខ្លីនិង៑ទំហំតូចជាង៑ ដែលមានប្រវែង៑ជាមធ្យមគ្របជិតត្រគាកចាប់ពី១,៦០ម៉ែត្រឡើង៑ទៅ និង៑ទទឹង៑ជាមធ្យម០,៥០ម៉ែត្រ។

- (៣). **ស្បៃតាត** ជាស្បៃធ្វើពីសាច់កំណាត់ពណ៌ាមាស ប្រាក់ ឬស្ពាន់ ដែលច្រើនទាំចូលពីឥណ្ឌានិងពែក្ស ហើយច្រើនមានប្រវែងជាមធ្យមគ្របជិតត្រគាកចាប់ពី ១,៦០ម៉ែត្រឡើងទៅ និងទទឹងជាមធ្យម០,៥០ម៉ែត្រ។
- (៤). **ស្បៃធំ** ឬហៅថា **ស្បៃច្រក-ក** ឬខ្លះហៅថា **ស្បៃក្ងោះ** ជាស្បៃដែលមានប្រវែងជាមធ្យមចាប់ពី ១,៦០ម៉ែត្រ ដល់ ១,៧០ម៉ែត្រឡើងទៅ គ្របជិតទៅលើស្មាទាំងសងខាងដោយគេទុកចន្ងោះសមល្មមនឹងស៊កក្បាលចូល។
- (៥). **ស្បៃជីបក្ងី** ឬហៅថា **ជាហ៊ីមជីបក្ងី** ជាប្រភេទស្បៃស្តើងមានច្រើនពណ៌ា ដោយគេយកកំណាត់លាតធម្មតាមកបត់ជាផ្នត់អង្កាញ់តូចៗ ហើយមានប្រវែងជាមធ្យម ៣ម៉ែត្រ។
- (៦). **ស្បៃក្រួយ** ជាស្បៃមានសណ្ឋានត្រង់ស្មើ រាងបួនជ្រុងទ្រវែងគ្មានខ្វៀល សាច់ក្រាស់ ប្រវែងចន្ងោះពី ២ម៉ែត្រ ដល់ ២,៥ម៉ែត្រ។
- (៧). **ស្បៃផ្សេងៗ** ជាស្បៃលាតគ្មានក្បាច់លម្អ សាច់ស្តើងវែង កាគច្រើនពណ៌ាស ឬខ្មៅធ្វើពីសូត្រឬអំបោះ ដែលប្រើប្រាស់បានគ្រប់ស្រទាប់វណ្ណៈ ពោល គឺទាំងស្ត្រីវ័យចំណាស់ និងប្រជាជនទូទៅសម្រាប់ទៅវត្ត ឬកម្មវិធីផ្សេងៗ ដោយប្រើជាមួយសំពត់ក្បិន។

សរុបមក ស្បៃខ្មែរមិនត្រឹមតែជាគ្រឿងសម្អែកបំពាក់សម្រាប់គ្របដណ្តប់កាយ ឬបង្កើនសោភ័ណភាពរបស់ស្ត្រីប៉ុណ្ណោះទេ ប៉ុន្តែវាជានិមិត្តរូបតំណាងឱ្យភាពថ្លៃថ្នូរ សុភាពរាបសារ និងលក្ខណៈដ៏ឧត្តុង្គឧត្តមរបស់ស្ត្រីខ្មែរ ដែលមានប្រវត្តិសាស្ត្រចាក់ឫសយ៉ាងជ្រៅនៅក្នុងវប្បធម៌ខ្មែរ។ តាមរយៈកសុតាងប្រវត្តិសាស្ត្រជាច្រើនដូចជា សិលាចារឹកស.វ.ទី៧ (សិលាចារឹកវត្តគំនូរ) និងស.វ.ទី៩ (សិលាចារឹកព្រះគោ) ចម្លាក់ប្រាសាទបុរាណ គំនូរបុរាណ និងរឿងព្រេងនិទាន បានបញ្ជាក់យ៉ាងច្បាស់ថា ការប្រើប្រាស់ស្បៃមានអាយុកាលយូរលង់ណាស់មកហើយក្នុងសង្គមខ្មែរ។ បន្ថែមពីនេះ ស្បៃខ្មែរមានលក្ខណៈសម្បូរណ៌បែបយ៉ាងខ្លាំង ពោល យ៉ាងហោចណាស់ក៏គេអាចចាត់ថ្នាក់ស្បៃបានចំនួន ៧ប្រភេទដែរ (ស្បៃខ្វៀល ស្បៃធ្យៃ ស្បៃតាត ស្បៃធំ ស្បៃជីបក្ងី ស្បៃក្រួយ និងស្បៃផ្សេងៗ)។ ស្បៃទាំងអស់នេះបានបង្ហាញឱ្យឃើញពីភាពថ្នៃប្រតិដ្ឋ និងកម្រិតវប្បធម៌ដ៏ចំណានរបស់បុព្វបុរសខ្មែរក្នុងការតុបតែងកាយតាមហានៈ ពេលវេលា និងពិធីការផ្សេងៗ។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

បញ្ជីឯកសារពិគ្រោះ

អាង ជូលាន, "នគរគោកធ្លក", *អត្ថបទផ្សាយអនឡាញនៅក្នុង បណ្តាញព័ត៌មានវប្បធម៌ខ្មែរ, តាមរយៈតំណភ្ជាប់ https://www.yosothor.org/publications/khmer-renaissance/chapter-three/NokorKokthlok.html*


ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧, *វចនានុក្រមខ្មែរ*, ភ្នំពេញ។

អគ្គនាយកដ្ឋានបេតិកភណ្ឌវប្បធម៌អូបី និងឧស្សាហកម្មវប្បធម៌ច្នៃប្រតិដ្ឋ ២០២៦, *ស្បៃខ្មែរ មរតកសិល្បៈ និងអត្តសញ្ញាណវប្បធម៌*, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

Coedès, G. 1937, *Inscription du Cambodge*, Tome I. Hanoi.

Coedès, G. 1950, *Inscription du Cambodge*, Tome II. Hanoi.





រូបលេខ១៖ ចម្លាក់ទេពអប្សរនៅជញ្ជាំងប្រាសាទអង្គរវត្ត ធ្វាក់នៅស.វ.ទី១២ (ប្រភព៖ ទេសចរណ៍-Tourism)

រូបលេខ២៖ ចម្លាក់ស្ត្រីពានាស្បៃនៅជញ្ជាំងប្រាសាទអង្គរវត្ត ធ្វាក់នៅស.វ.ទី១៦ (ប្រភព៖ បុរាណាចារ្យ)





រូបលេខ៣-៤៖ គំនូរបុរាណនៅវត្តក្តីដើម ទ.ស.១៩៣០ បង្ហាញអំពីស្ត្រីខ្មែរពានាស្បៃ



រូបលេខ៥៖ ស្បៃខ្ចៀល (ប្រភព៖ អគ្គនាយកដ្ឋានបេតិកភណ្ឌវប្បធម៌អូបី និងឧស្សាហកម្មវប្បធម៌ច្នៃប្រតិដ្ឋ)

អត្តបទដោយ៖ ម៉ង់ វ៉ាលី





រូបលេខ៦៖ ស្ត្រីរបាំខ្មែរពាក់ស្បៃធៀង ថតនៅឆ្នាំ១៩៥១ (ប្រភព៖ EFEO Collection)
រូបលេខ៧៖ ព្រះមហាក្សត្រីយានីស៊ីសុវត្ថិមុនីវង្ស កុសម:នារីរ័ត្ន សេរីវឌ្ឍនា គ្រងស្បៃតាត (ប្រភព៖ វណ្ណ ម៉ូលីវណ្ណ, ១៩៦៥)





រូបលេខ៨៖ ស្ត្រីរបាំខ្មែរពាក់ស្បៃធំ ឬស្បៃច្រក-ក ថតនៅទ.ស.១៩៥០ (ប្រភព៖ gallica.bnf.fr)
រូបលេខ៨៖ ស្ត្រីខ្មែរពាក់ស្បៃជីបក្ងី (ប្រភព៖ gallica.bnf.fr)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី





រូបលេខ១០៖ លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត ពាន់ស្បៃក្បួយ (ប្រភព៖ Chanmony Pich)

រូបលេខ១១៖ ស្ត្រីចំណាស់ខ្មែរពាន់ស្បៃនៅផ្ទះ (ប្រភព៖ gallica.bnf.fr)

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី